## ព្រះរាជក្រម នស/រកម/០៧០០/០៣

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈ ដូចមានរាយនាមខាងក្រោមនេះ :

១-កិច្ចព្រមព្រៀងស្តីពីការជំរុញកិច្ចសហប្រតិបត្តិការលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពវប្បធម៌ធ្វើនៅភ្នំឃែមេរ៉ុន នាថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៦៩

២-កិច្ចព្រមព្រៀងពហុភាគីស្តីពីសិទ្ធពាណិជ្ជកម្មលើសេវាក្រៅកម្មវិធីរវាងប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ធ្វើនៅម៉ានិល នាថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៧១

៣-កិច្ចព្រមព្រៀងលើការសំរួលក្នុងការរុករកយន្តហោះក្នុងភាពអាសន្ននិងការសង្គ្រោះជនដែលនៅរស់ក្រោយពីគ្រោះថ្នាក់យន្តហោះ ធ្វើនៅសឹង្ហបូរិនា ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧២

៤-កិច្ចព្រមព្រៀងលើការសំរួលក្នុងការរុករកនាវាក្នុងភាពអាសន្ននិងការសង្គ្រោះជនដែលនៅរស់ក្រោយពីគ្រោះថ្នាក់នាវា ធ្វើនៅគូឡាលំពួរ នាថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៥

៥-កិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅបាលី នាថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ដែលរួមមានពិធីសារនិងកិច្ចព្រមព្រៀងពាក់ព័ន្ធដូចខាងក្រោមនេះ :

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅបាងកក នាថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៣

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅគូឡាលំពួរ នាថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៨៥

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅបាន់ដាសេរីបេហ្គាវ៉ាន់ នាថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៨៩

-ពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីការបង្កើតលេខាធិការដ្ឋានអាស៊ាន ធ្វើនៅម៉ានិល នាថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៩២

៦-កិច្ចព្រមព្រៀងស្តីពីសន្តិសុខស្បៀងបំរុងរបស់អាស៊ាន ធ្វើនៅ ញូវយ៉ក នាថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៩

៧-កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ប័ណ្ណបើកបរក្នុងស្រុកចេញដោយបណ្តាប្រទេសអាស៊ាន ធ្វើនៅគូឡាលំពួរ នាថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៨៥

៨-កិច្ចព្រមព្រៀងស្តីពីការអភិរក្សធម្មជាតិនិងធនធានធម្មជាតិធ្វើនៅគូឡាលំពួរ នាថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៨៥

៩-កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានផ្នែកថាមពលធ្វើនៅម៉ានិល នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦

១០-កិច្ចព្រមព្រៀងស្តីពីសន្តិសុខប្រេងឥន្ធនៈអាស៊ាន ធ្វើនៅម៉ានិល នាថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦

១១-កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសដោយអនុគ្រោះយកអ្នកស្នើសុំដេញថ្លៃអាស៊ានសំរាប់ម៉ៅការ ធ្វើនៅហ្សាការតា នាថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៨៦

១២-កិច្ចព្រមព្រៀងអាស៊ានស្តីពីការជំរុញនិងការពារវិនិយោគទុន ធ្វើនៅម៉ានិល នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៨៧ និងពិធីសារនៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ធ្វើនៅហ្សាការតា នាថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៦

១៣-កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន ធ្វើនៅសិង្ហបុរី នាថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩២

១៤-កិច្ចព្រមព្រៀងស្តីពីតារាងអនុគ្រោះពន្ធគយមានប្រសិទ្ធភាពរួម (CEPT) សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ធ្វើនៅសិង្ហបុរី នាថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩២

១៥-កិច្ចព្រមព្រៀងស្តីពីការបង្កើតមូលនិធិអាស៊ាន ធ្វើនៅបាងកក នាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៤

១៦-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា ធ្វើនៅបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

១៧-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា ធ្វើនៅបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

១៨-កិច្ចព្រមព្រៀងជាមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន ធ្វើនៅសិង្ហបុរី នាថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦

១៩-ពិធីសារស្តីពីយន្តការដោះស្រាយវិវាទ ធ្វើនៅម៉ានិល នាថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

២០-កិច្ចព្រមព្រៀងអាស៊ានស្តីពីគយ ធ្វើនៅភូកេត នាថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៧

២១-កិច្ចព្រមព្រៀងស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ាន សំរាប់ថាមពល ធ្វើនៅម៉ានិល នាថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៨

២២-កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់វិញ្ញាបនប័ត្រត្រួតពិនិត្យយានយន្តពាណិជ្ជកម្មសំរាប់ដឹកជញ្ជូន ទំនិញនិងសេវាយានយន្តសាធារណៈ ដែលផ្តល់ដោយបណ្តាប្រទេសអាស៊ាន ធ្វើនៅសិង្ហបុរី នាថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៨

២៣-កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីតំបន់វិនិយោគទុនអាស៊ាន ធ្វើនៅម៉ាកាទី នាថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៨

២៤-ពិធីសារស្តីពីនីតិវិធីនៃការជូនដំណឹង ធ្វើនៅម៉ាកាទី នាថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨

២៥-កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសំរបសំរួលក្នុងការទទួលស្គាល់គ្នាទៅវិញទៅមក ធ្វើនៅហាណូយ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨

២៦-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសំរួលដល់ទំនិញឆ្លងកាត់ ធ្វើនៅហាណូយ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨

២៧-អនុស្សរណៈស្តីពីការបង្កើតគ្រឹះស្ថានអាស៊ាន ធ្វើនៅគួឡាឡំពួរ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់ជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈខាងលើនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

ព្រះហស្តលេខា
នរោត្តម សីហនុ

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

★★★

## ព្រះរាជក្រម នស/រកម/០៧០០/០៨

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨